HONEYCOMB 3/2 (April 2002): 41–54



# A Christian Response to Disability in Cambodia

*Glenn MILES*

## An Introduction to Disability in Cambodia

One out of twenty children are born with a disability or become disabled during their childhood. The following is a global estimate based on research. Cambodia probably suffers higher percentages in some areas, but this chart gives some idea of the extent of the problem.

| *Type Of Limitation* | *Prevalence%* |
|---|---|
| **Moving difficulty** | 2.0 - 2.5 |
| **Seeing difficulty** | 0.5 - 0.8 |
| **Hearing/speech difficulty** | 0.5 - 0.8 |
| **Learning difficulty** | 0.2 - 0.4 |
| **Chronic fits** | 0.3 - 0.6 |
| **Strange behavior** | 0.1 - 0.2 |
| **Feeling difficulty (in hands or feet)** | 0.1 - 0.2 |
| **Cambinations of the above** | 0.2 - 0.3 |
| **TOTAL** | 4% - 5% |

Source: Helander, E (1993) 'Prejudice & Dignity' UNDP

*Fig. 1. United Nations description of prevalence of disability according to limitation rather than diagnosis.*

We might expect disability to affect all classes equally. But actually it is the poorest children who are most likely to be disabled due to the inadequate care their mothers receive during pregnancy and delivery, the unsafe environments in which the children live, and the lack of available care and support that compounds their disabilities.

Though Cambodia's conflict is past, children continue to be susceptible to injury and permanent disability from landmines and other unexploded ordnance. Those who did suffer wartime injuries might later find these exacerbated by subsequent mental trauma, or through separation from or loss of family members.

Poverty can also force children to work in dangerous occupations. In construction or road building sites, or in factories, children can suffer injury due to inadequate or no safety precautions. Advocacy for safe working conditions and against all forms of intolerable labor is therefore crucial for working children. Street children—who literally live and work on the streets—are at great risk of being disabled through traffic accidents. They are also less likely to receive treatment, care, or support after injury, and so suffer greater risk of complications.

## Our Attitude is the Biggest Disability of All

When I first wrote this article I kept referring to "disabled children." Readers rightly criticized this phrase, because children with disabilities are *first* "children," and *then* "disabled." This criticism reminds us how we must look at and work with children with disabilities. The labeling of children is one of their most profound disabilities. In fact, Cambodian children with disabilities experience some of the deepest discrimination of all children.

When I worked in Site 2 refugee camp, a number of young men were banished to one end of the camp to an "orphanage" for boys who had lost their limbs to landmines while fighting in the war. Even though they had fought for their country, they were despised by many of the community because they were disabled. So they endured a double tragedy—first losing a limb, and second losing the support of their loved ones. Some were so depressed that they agreed to act as assassins to kill people in the camp for a fee. I was glad to see the church taking

services to the young men on Sunday, and I remember asking one boy what he wanted us to pray for. Instead of asking that his limb would grow back he asked that his heart be mended. We prayed for a touch from God, but it was terribly sad.

Dr. Sue Jack from Servants to Asia's Urban Poor describes some of the problems of fatalism. "Because 95% of Cambodian people are Buddhist, disability here is often regarded as due to bad *karma,* either of the parents or of the child. Social and financial disadvantages accompany this assessment. So also does a feeling of helplessness, since the injury was decreed by 'fate' and therefore nothing can be done about it. Families who unsuccessfully seek help from traditional healers have less motivation to approach the fledgling disability services that are now appearing in Cambodia. The sense of fatalism and 'unfortunate destiny' means that children are often 'hidden' from view in the back of the house and at times neglected, so finding children needs to be very proactive."

### How are Christian Organizations Dealing with this Issue?

As well as Catholic ministries to people with disabilities at Wat Tan, and the Marist Lavalla School, a number of Protestant organizations also work with people with disabilities. It is exciting to see organizations like Servants address the problem of disability in their community of Srok Mean Chey.

Dr. Sue Jack describes the work of Servants, "We try to mainstream the children into schools if possible, advocate at the local schools on their behalf, and provide any equipment necessary to make mainstreaming possible. For example, we may build ramps. Once a week we have a therapy/play session where caregivers are taught appropriate exercises, reinforcement, and good caring practice for their children."

Servants does not give families false expectations. "We stress that it will be the caregivers' commitment to the child that will help him or her improve, not our expertise, and that it will be a long, slow process. We therefore do all we can to provide ongoing support for the whole family, making sure they understand advice given—for example, how to perform the exercises. Our work also provides a

great opportunity for families to meet one another. We facilitate links between old families and new, so that they may encourage each other in what progress is possible. This speaks much louder and has much more impact than anything we can say."

As well as prejudice towards disability, some people must combat racial prejudice as well. "We are seeing Khmer, Cham (Muslim), and an increasing number of Vietnamese children. One of our staff speaks fluent Vietnamese, and our health district has a significant number of Vietnamese families who are socially marginalized and therefore experience difficulty in accessing health care in Cambodia."



*Fig. 2. Mr. Sam Ouen*

*Director of Cambodian Association of Farmers and the Poor*

Another organization working in this field is the Cambodian Association for Development of Farmers and the Poor in Kampot. The director, Mr. Sam Ouen (Fig. 2), is himself disabled and hence an excellent role model. He demonstrates that, with God's help and personal determination, an individual can do exceptional things. He recently put together a photo-journal of several children in their community (Fig. 3). The journal demonstrates his philosophy that, if a deed is possible, then it should be attempted and done. The children attend school, cook, play, assist with household chores, and work in the fields alongside their peers. The program supports families through a cow-pig bank,



*Fig. 3a. The children at play*



*Fig. 3b. The children assist with household chores*

which helps families who are more vulnerable because of a child's disability (for example when a family member cannot work because he or she needs to look after a child).

Children are sometimes so severely disabled that their families prove unwilling or unable to keep them. Some parents of the severely handicapped resort to infanticide. Even where this does not happen the infant may well die from malnutrition, malaria, or chest infection in the first year. If the child survives infancy, he or she is likely to live for some time and require a long-term commitment.

The Group Homes currently supported by YWAM and X-PACT care for some of these children with severe disabilities. They were started in an attempt to develop alternatives to large institutions for children with disabilities who had already been abandoned. These ministries recognize the abilities such children possess, as well as their rights to dignity, love, support, and care in a community. Such active compassion for the disabled seems to be a predominately Christian trait. While Christianity is not the only faith that exercises such compassion, the number of organizations working with the disabled that spring from other faiths is very small.

## What is Disability and What is Impairment?

Tearfund believes that we should focus more on what the child *can* do than on what she or he *cannot* do. The World Health Organization (WHO) International Classification of Impairments and Handicaps (version 2, Fig. 4) employs the concept of *disablement*. This moves away from the strict medical model in an attempt to define the causes and effects of disability in a more positive way. The terms *disability* and *handicap* have been replaced by the more positive concepts of *activities* and *participation*. However, we must remember that, "words can be politically correct and well packaged, but the majority of people with disabilities are lonely, lost, isolated and often ostracized by society."[1] A change of words alone is not enough but a genuine attitude of Christ-like servanthood.

---

[1]Nigel Poulton of World Concern, personal communication.

| *Term* | *Definition* |
|---|---|
| **Impairment** | A loss or abnormality of a body part (i.e. structure) or body function (i.e. psychological function). The psychological functions include mental functions. |
| **Activity** | Everything a person does from simple activities (e.g. grasping, moving a leg, seeing) to complex skills and behaviors (e.g. remembering past events or acquiring knowledge). |
| **Activity limitation (formerly disability)** | Difficulty in the performance, accomplishment, or completion of an activity at the level of the person because of, e.g., pain/discomfort, doing it too slowly/quickly, or not at the right time/place. |
| **Participation** | Participation consists of all areas or aspects of human life, including full experience of being involved in practice, custom, or social behavior. |
| **Participation Restriction** | The disadvantage for a person with impairment that is created or worsened by environmental and personal factors. |

Source: WHO ICIDH - 2 (1997)

*Fig. 4. WHO International Classification of Impairments and Handicaps.*

The Medical Model of disability adhered to by many doctors views impairment as an "abnormality" that needs to be "corrected," "cured," or "overcome." It is based on the concept that while the human body is alterable the social environment is not. The Social Model of disability developed by community-based practitioners stresses that a handicap or disability is a relationship between an individual and his/her environment, and emphasizes the role societies play in disabling a person.[2]

## What Does the Bible Say about Disability?

*Those parts of the body that seem to be weaker are indispensable, and the parts that we think are less honorable we treat*

[2]Hartley, Sally, and Sheilah Wirz, 1993.

*with special honor. . . . Now you are the body of Christ and each of you is a part of it.*[3]

Each child is uniquely created in the image of God and bears inherent worth.[4] If maturity is defined as "attaining to the whole measure of the fullness of Christ"[5] in whom "all the fullness of the Deity lives in bodily form,"[6] then for all children a limit exists as to how far maturity will be achieved. Christians believe this to be true whether or not a child has a physical or mental disability. In fact, none of us will reach complete wholeness or maturity until we reach heaven. Even Jesus had to live out his life in human form with all the limitations that human bodies impose. Dr. Peter Sidebotham, who previously worked with Servants in Cambodia, says, "Children with a disability or without one need to be encouraged to reach the full degree of their God-given potential."

Nevertheless, "the concept of wholeness is very much a part of accepting and understanding that disability is simply a small part of who a person is." Thus says Rev. Dr. Nancy Lane, who herself is disabled. Children with disabilities are "whole" as they are, and to imply otherwise perpetuates negative stereotypes. "It also perpetuates the notion that a disabled body means one is not a whole person—thinking, sexual, with same needs and desires as non-disabled."[7]

By contrast, in Cambodia children with disabilities are often viewed as liabilities consuming precious resources. They are therefore not priorities for communities, most government and health departments, and even families.

All of us need to experience God's love. Unfortunately, children with disabilities more than other children may experience prejudice and rejection from an early age. So the response of the church must provide an alternative and loving environment. It can be painful to be "different," but in God's "upside-down" Kingdom, "to shame what is strong, God has chosen what the world counts weakness."[8]

---

[3]1 Cor 12:22–23, 27.

[4]Gen 1:26.

[5]Eph. 4:13.

[6]Col. 2:9.

[7]Nancy Lane, personal communication.

[8]1 Cor 1:25–31.

Some key biblical characters like Moses[9] and St. Paul[10] had impairments. Mel Horne from "Church Action on Disability" suggested, "This wouldn't have been the case if God didn't mean impaired people to be around." Both Moses and Paul were specifically chosen for their tasks of spreading God's message, yet God informed Moses regarding his speech impediment, "I made you thus." Paul's body metaphor in 1 Corinthians 12 suggests that all people (including children with disabilities) are created to reveal the interdependence of human beings (rather than dependence or supposed independence).

Disability is not due to the sin or lack of faith of the child or parents. It may be a wonderful revelation for a child with disabilities to find that God loves her unconditionally, and that she has equal access to him in prayer and worship like any other person. "I call you by name," says the Lord. "You are mine" (Isaiah 43:1).[11]

Jesus himself chose to retain the marks of crucifixion after his resurrection, when as a perfect being he might have chosen to bear no scars. Instead, Jesus invited his disciples to touch the holes in his body. In so doing he is "challenging the way non-disabled people avoid those with disabilities."[12] "By his wounds we are healed."[13]

The New Testament church was continually encouraged to reach out to those with whom they wouldn't normally feel comfortable, and to love them unconditionally. The story of the Good Samaritan serves as an example. Jean Vannier founded the L'Arche communities, where people both with and without disabilities live together in community. Vannier has observed, "Loving someone is not doing things for them but revealing to them that they are precious." It is important that children with disabilities are not seen as existing only to enable others to serve God better. This could give the message that the server is more important than the recipient.

---

[9]Ex 4:10–11.

[10]2 Cor 12:9.

[11]Faith Bowers, 1996.

[12]Taylor & McCloughry, 1998.

[13]Isa 53:5.

**What is the Best Way to Help Children with Disabilities?**

Historically, children with disabilities, especially those who were described as "mentally retarded," were kept out of site in huge asylums. For example, London is surrounded by a ring of asylum hospitals. Alternatively, children were put into special institutions such as schools for the blind. These ideas were exported to the developing world, so that governments and Christian organizations have until recently viewed institutions as the main way of dealing with the "problem" of disability.

However, things are gradually changing. United Nations Development Program research[14] indicates that service delivery programs for people with disabilities in third-world countries would benefit from incorporating the following principles:

1. Mobilizing the family and community.
2. Empowering people with disabilities themselves.
3. Changing attitudes of people towards disability.

These principles mirror the biblical principles of supporting the family, supporting and encouraging the vulnerable, and harboring no prejudices towards those who are not the same as ourselves.

It is hoped that good community-based rehabilitation will enable many families to keep their children with disabilities with them, as communities are supported in every way to work with such children. By doing so they can experience the benefits and joys—as well as the heartaches and stresses—of raising a child with disabilities. Whether children can stay at home or not depends on their economic situation, community services that people are aware of, and sometimes what the doctor or midwife told the family at the child's birth.

It may also depend on the extent of their impairment and the presence of an older sibling, grandparent, or other adult to take responsibility for them. The main caregivers are usually immediate family. Their ability to work with a child with disabilities will depend on the family's work, chores, schooling needs, etc. They may require the support of their community and, where Christian, their church community.

---

[14]Helander, 1993.

The other way the issue of disability can be approached is through advocacy, in which the attitudes of the public, health, education, and social service/voluntary sector professionals—and of course parents—can be influenced to see beyond the disability to the ability of the child. As usual, though, the attitudes must start with ourselves and with the church. Do we welcome the disabled person into the church, or do we absorb the prejudices and inappropriate cultural norms and reject them? We must challenge our deep-seated fears and prejudices and ask, What Jesus would do?

## References

Bowers, Faith. *Treat with Special Honour: People with Learning Difficulties in the Life of the Church*. Oxfordshire: Baptist House, 1996.

Hartley, Sally, and Sheilah Wirz. "Investing Models of Service Delivery for People with Communication Disorders in Anglophone Africa," *Work in Progress*, vol. 3. NHCSS. University of London, 1993.

Helander, E. *Prejudice and Dignity: an Introduction to Community Based Rehabilitation*. New York: UNDP, 1993.

Horne, Mel. "Did God Create Impairment? A Bible Study." *All People: the Magazine of Church Action on Disability* (1998).

Sidebotham, P. *Child Development and Disability*. Unpublished, 1998.

Taylor, M., and McLoughry. "A Disabled God." *Third Way* (October 1998).

Through the Roof "Roofbreaker Guides." *Guidelines for Involving Children with Disabilities into Church Life*. UK: Through the Roof Ministries, 1999.

Wirz, Shelagh, and Winyard. *Hearing and Communication Disorders*. London: Macmillan, 1993.

Young, F. *Encounter with Mystery: Reflections on L'Arche and Living with Disability*. Darton, Longman & Todd, 1997.

*A group of essays by theologians after visiting the L'Arche communities.*

## Key Resources

Coleridge, Peter. *Disability, Liberation and Development*. Oxford: Oxfam Publications, 1993.

Eiesland, Nancy L. *The Disabled God: Towards a Libertory Theology of Disability*. Nashville: Abingdon, 1994.

*Looks at Jesus being "disabled" on the cross, and then at the meeting with the disciples after the resurrection.*

Ingstad, B. and Whyte, SR, ed. *Disability and Culture*. Berkeley: University of California Press, 1995.

Potter D. *Am I Beautiful . . . or What?* Oxford: Scripture Union, 1998.
*Information about learning disability, training material for individual or group use, essential guidance on running meetings for people with learning difficulties, a course of teaching materials for such meetings.*

Ransom, Judy Griffith. *The Courage to Care: Seven Families Touched by Disability and Congregational Caring.* Nashville: Upper Room Books, 1994.
*Chronicles the stories of people whose lives were dramatically changed by the caring of congregations, friends, and family. Important book for churches wanting to understand why and how caring is part of what it means to be a community and to offer hospitality.*

Webb-Mitchell, Brett. *God Plays Piano Too: The Spiritual Lives of Disabled Children.* N.p.: Crossroads, 1993.
*The stories of children with disabilities who had wonderful, but often hidden, gifts. Webb-Mitchell shows the church how to welcome and receive the gifts and "reveals the hidden wholeness that lies beneath the broken surface of all our lives."*

Webb-Mitchell, Brett. *Unexpected Guests at God's Banquet: Welcoming People with Disabilities into the Church.* N.p.: Crossroads, 1994.
*This is concerned with learning how to welcome people with disabilities and why doing so is essential for the church. "For it is only when we learn how to be with those who are different from us, and learn how to accept the love of God that we all need, that we will be able to sustain a community that is capable of worshipping God."*

Werner, David. *Disabled Village Children: A Guide for Community Health Workers, Rehabilitation Workers and Families.* Palo Alto, California: Hesperian Foundation, 1994.

____________. *Nothing about Us Without Us.* Palo Alto, California: Hesperian Foundation, 1998.
*Explores innovative aids that can be made at low cost. It also considers how people with disabilities and those without them can learn together.*

## Christian Resource Organizations

Church Action on Disability (CHAD), 50 Scrutton Street, London EC2A 4PH, UK. Tel: 44 171 452 2085; Fax: +44 171 452 2001; email: mlpcfm@aol.com
*Education and awareness raising of disability in churches. Produce access audit, resource pack, study pack and youth pack. Quarterly magazine* All people.

Deaf Christian Network, P.O. Box 212, Doncaster, South Yorkshire, DN2 5XA, UK Tel: +44 1302 369684 (Voice/Minicom); Fax: +44 1302 739660
*Resources for those working with profoundly deaf people.*

Disability Awareness and A Healing Ministry (The Rev. Dr. Nancy Lane). P. O. Box 274, Lansing, NY 14882-0274, USA. Tel: 607-533-4083 Email: nlane1@twcny.rr.com
*Resources for those working with women who have been abused or sexually exploited, including women with disabilities.*

Evangelical Alliance Disability Forum, 186 Kennington Park Road, London SE11 4BT, UK Tel: +44 171 207 2100; Fax: +44 171 207 2150
*Umbrella organization for Christian disability organizations.*

SPRED, Special Religious Education Department (Roman Catholic Church), c/o Brothers of Charity Services, Lissieux Hall, Whittle-le-Woods, Chorley, Lancashire PR6 7DX, UK. Tel: 44 1257 266 311
*Looks at spiritual needs of people with learning difficulties and provides suitable study and worship material.*

Through the Roof, P.O. Box 178, Cobham, Surrey, KT11 1YN Tel/Fax: +44 1932 866333; email: info@throughtheroof.org website: www.jafministries.com/throughtheroof
*The disability outreach of Joni Erickson Tada. Produces a series of one-page "Roofbreaker Guides" about including people with different types of disabilities in the church.*

Torch Trust for the Blind, Torch House, Hallaton, Market Harborough, Leicestershire, LE16 8UJ, UK. Tel: +44 1858 555301; Fax: +44 1858 555371
*Christian resources for blind and visually impaired people.*

សំណុំឆឹកឃ្មុំ ៣/២ (មេសា ២០០២)៖ ៥៥-៧៤



# ការឆ្លើយតបរបស់គ្រីស្ទបរិស័ទ ចំពោះភាពពិការ នៅក្នុងប្រទេសកម្ពុជា

*លោក គ្លេន ម៉ែល*

## ការណែនាំឲ្យស្គាល់ចំពោះភាពពិការនៅក្នុងប្រទេសកម្ពុជា

មានក្មេងម្នាក់ក្នុងចំណោមក្មេងចំនួន២០នាក់ ដែលបានកើតមកដោយមានភាពពិការតាំងពីកំណើត ឬពិការកាលពីនៅកុមារ ។ តទៅនេះ គឺជាការប៉ាន់ប្រមាណជាទូទៅដោយផ្អែកទៅលើការស្រាវជ្រាវ ។ ប្រទេសកម្ពុជា

| *ប្រភេទនៃការកំណត់* | *ចំនួនភាគរយជាទូទៅ* |
|---|---|
| ពិបាកក្នុងការធ្វើចលនា | ២.០ - ២.៥ |
| ពិបាកក្នុងការមើល | ០.៥ - ០.៨ |
| ពិបាកក្នុងការស្តាប់/ពិបាកក្នុងការនិយាយ | ០.៥ - ០.៨ |
| ពិបាកក្នុងការរៀនសូត្រ | ០.២ - ០.៤ |
| ប្រកាច់រ៉ាំរ៉ៃ | ០.៣ - ០.៦ |
| មានអាកប្បកិរិយាមិនប្រក្រតី | ០.១ - ០.២ |
| ដៃ ឬជើងស្ពឹក | ០.១ - ០.២ |
| មានបញ្ហាទាំងអស់ខាងលើ | ០.២ - ០.៣ |
| សារុប | ៤% - ៥% |

Source: Helander, E (1993) 'Prejudice & Dignity' UNDP

*រូបទី ១: United Nations description of prevalence of disability according to limitation rather than diagnosis.*

ប្រហែលជាមានការទទួលរងនូវការឈឺចាប់ខ្ពស់ជាងគេនៅក្នុងផ្នែកខ្លះ ប៉ុន្តែតារាងនេះនឹងបង្ហាញឲ្យយើងមានគំនិតខ្លះៗពីបញ្ហាទាំងនោះ ។

យើងប្រហែលជាអាចសង្ស័យថា ភាពពិការនេះនឹងមានឥទ្ធិពលលើគ្រប់ផ្នែកទាំងអស់ស្មើៗគ្នា ។ ប៉ុន្តែតាមពិតទៅ បញ្ហាដែលធ្ងន់ធ្ងរនោះកើតឡើងចំពោះកុមារដែលក្រីក្របំផុត ព្រោះតែមិនមានការថែទាំបានល្អគ្រប់គ្រាន់ពីម្តាយរបស់គេនៅក្នុងអំឡុងពេលដែលកុមារនោះនៅក្នុងផ្ទៃម្តាយ និងក្នុងអំឡុងពេលសំរាល បរិយាកាសដែលនៅជុំវិញមិនមានសុវត្ថិភាពចំពោះការរស់នៅរបស់កុមារនោះ ព្រមទាំងខ្វះខាតការថែទាំ និងការគាំទ្រដែលជាហេតុនាំឲ្យបន្ថែមទម្ងន់ដល់ភាពពិការរបស់គេថែមទៀត ។

ថ្វីដ្បិតតែបញ្ហារបស់ប្រទេសកម្ពុជាបានកន្លងផុតហើយក៏ពិតមែន តែកុមារនៅតែបន្តទទួលនូវការរងគ្រោះថ្នាក់ដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដទៃទៀតដែលជាហេតុធ្វើឲ្យកុមារធ្លាក់ខ្លួនពិការ ។ ចំពោះអ្នកដែលទទួលរងគ្រោះនៅក្នុងពេលសង្គ្រាមនោះ អាចនឹងមានការរងគ្រោះកាន់តែធ្ងន់ធ្ងរឡើងៗដោយសារផលប៉ះពាល់ផ្នែកផ្លូវចិត្ត ឬដោយសារបែកបាក់ ឬបាត់បង់សមាជិកគ្រួសាររបស់គេ ។

ភាពទីទ័លក្រអាចជាហេតុបង្ខំឲ្យកុមារធ្វើការនៅក្នុងមុខរបរដែលប្រកបទៅដោយគ្រោះថ្នាក់ផងដែរ ។ កុមារអាចទទួលរងរបួសក្នុងការងារសំណង់ ការធ្វើថ្នល់ ឬការងារនៅក្នុងរោងចក្រ ដោយព្រោះមិនមានការប្រុងប្រយ័ត្នគ្រប់គ្រាន់ ឬក៏គ្មានសុវត្ថិភាពគ្រប់គ្រាន់ ។ ការគស៊ូមតិសំរាប់សុវត្ថិភាពការងារ និងការប្រឆាំងចំពោះការប្រកបការងារដ៏លំបាកដែលប្រកបដោយគ្រោះថ្នាក់គ្រប់ប្រភេទទាំងឡាយ នោះជារឿងសំខាន់សំរាប់កុមារដែលកំពុងធ្វើការងារនោះ ។ កុមារអនាថា ដែលរស់នៅតាមដងវិថី និងធ្វើការរកស៊ីនៅតាមដងផ្លូវនានា គឺជាក្រុមមួយដែលមានគ្រោះថ្នាក់ខ្ពស់ជាងគេ ដោយព្រោះគ្រោះថ្នាក់ចរាចរ ។ ពួកក្មេងទាំងនោះមិនសូវបានទទួលនូវការព្យាបាល

ការថែទាំ ឬការគាំទ្រឡើយ បន្ទាប់ពីទទួលរងរបួសរួចមកហើយ តែងតែមានការរងគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុតប្រកបដោយភាពស្មុកស្មាញជាទីបំផុត ។

## ឥរិយាបថរបស់យើងគឺជាភាពពិការដ៏ធំបំផុត

នៅពេលដែលខ្ញុំចាប់ផ្ដើមសរសេរអត្ថបទនេះ ខ្ញុំតែងតែនឹកទៅដល់ "កុមារពិការ" ជានិច្ច ។ មិត្តអ្នកអានអាចមានសិទ្ធិគ្រប់គ្រាន់ក្នុងការរិះគន់ចំពោះដំណាក់ការនេះ ពីព្រោះកុមារដែលមានភាពពិការនោះ គឺមុនដំបូង "កុមារ" ហើយបន្ទាប់មក "ពិការ" ។ ការរិះគន់នេះធ្វើឲ្យយើងនឹកឃើញពីរបៀបដែលយើងត្រូវពិនិត្យមើល និងការងារដែលយើងត្រូវធ្វើជាមួយកុមារពិការទាំងឡាយនោះ ។ ការលាបពណ៌(ការវាយផ្លាក)ដល់កុមារ នោះជាបញ្ហាមួយដ៏សំខាន់បំផុតចំពោះភាពពិការរបស់កុមារ ។ តាមពិតទៅកុមារកម្ពុជាដែលមានភាពពិការនោះ ទទួលរងនូវការប្រកាន់វណ្ណៈយ៉ាងធ្ងន់ធ្ងរបំផុតជាងកុមារទាំងអស់ ។

នៅពេលដែលខ្ញុំធ្វើការនៅជំរំជនភៀសខ្លួន សាយធូ មានមនុស្សជំទង់មួយក្រុមដែលគេបញ្ជូនឲ្យទៅនៅចុងជំរំម្ខាងគឺជាកន្លែង "មណ្ឌលកុមារកំព្រា" សំរាប់ក្មេងប្រុសដែលបាត់បង់អវយវៈដោយសារតែគ្រាប់មីននៅពេលដែលគេចូលប្រយុទ្ធក្នុងសមរភូមិ ។ ទោះបីជាគេប្រយុទ្ធក្នុងបុព្វហេតុប្រទេសជាតិរបស់ខ្លួនក៏ដោយ ពួកគេត្រូវទទួលនូវការស្អប់ខ្ពើមពីសំណាក់អ្នកដែលរស់នៅក្នុងសហគមន៍ ដោយសារតែពួកគេត្រូវធ្លាក់ខ្លួនពិការ ។ ដូច្នេះគេត្រូវទទួលរងនូវវិនាសកម្មពីរដង គឺទីមួយការបាត់បង់អវយវៈរបស់ខ្លួន និងទីពីរការបាត់បង់ការគាំទ្រពីអ្នកដែលជាទីស្រឡាញ់របស់ខ្លួន ។ ជនពិការមួយចំនួនមានការធ្លាក់ទឹកចិត្តយ៉ាងខ្លាំង ដែលជាហេតុបណ្ដាលឲ្យគេហ៊ានទៅស៊ីឈ្នួលសម្លាប់មនុស្ស ។ ខ្ញុំសប្បាយរីករាយណាស់ដោយឃើញថា ក្រុមជំនុំមានចំណែកជួយមនុស្សជំពូកនេះនៅថ្ងៃអាទិត្យ

ហើយខ្ញុំនៅចាំបានថាខ្ញុំបានសួរក្មេងប្រុសម្នាក់ថា តើចង់ឲ្យយើងអធិស្ឋានអ្វីសំរាប់វា ។ វាមិនបានសុំឲ្យយើងអធិស្ឋានឲ្យជើងរបស់វាដុះឡើងវិញនោះទេ តែវាបានសុំឲ្យយើងអធិស្ឋានសំរាប់ការផ្សះផ្សាដួងចិត្តរបស់វាទៅវិញ ។ យើងបានអធិស្ឋានសុំការប៉ះពាល់ពិសេសពីព្រះជាម្ចាស់ ប៉ុន្តែបែរទៅជាបានការសោកសៅទៅវិញ ។

វេជ្ជបណ្ឌិត *ស៊ូ ជែក* នៃអង្គការបំរើជនក្រីក្របានពណ៌នាប្រាប់ពីបញ្ហាខ្លះថា គឺមិនអាចកែកុនបានឡើយ ។ "ពីព្រោះ ៩៥% នៃប្រជាជនកម្ពុជាជាអ្នកកាន់តាមលទ្ធិព្រះពុទ្ធសាសនា ការធ្លាក់ខ្លួនពិការនេះ ជារឿយៗទាក់ទងទៅនឹងកម្មផលរបស់ឪពុកម្តាយ ឬរបស់កូននោះទៅវិញទេ ។ បញ្ហាសង្គម និងបញ្ហាហិរញ្ញវត្ថុ ដើរស្របនឹងការយល់ឃើញលើកម្មផលនេះតែម្តង ។ ដូច្នេះការមានអារម្មណ៍កណ្តោចកណ្តែងនោះក៏ដូចគ្នាដែរ ដោយហេតុថា គេបានយកការរងរបួសនេះទៅផ្អែកលើ "ព្រេងវាសនា" ទៅវិញ ទើបគ្មានអ្វីដែលអាចកែប្រែបានឡើយ ។ គ្រួសារទាំងឡាយដែលបរាជ័យក្នុងការស្វែងរកជំនួយពីគ្រូខ្មែរនោះ គឺមិនសូវចាប់អារម្មណ៍ក្នុងការស្វែងរកជំនួយផ្នែកជនពិការដែលមាននៅក្នុងប្រទេសកម្ពុជាប៉ុន្មានទេ ។ ការមានអារម្មណ៍ថាមិនអាចកែកុនបាន និងការមានវាសនាអកុសល មានន័យថា កុមារតែងតែ "ខំលាក់ខ្លួន" ពួនអាត្មា គេចមុខពីគេឯង និងតាមធម្មតាមិនអើពើក្នុងការថែទាំពីអ្នកដទៃ ដូច្នេះយើងយល់ឃើញថា កុមារត្រូវការឲ្យមានការផ្តួចផ្តើមយ៉ាងសស្រាក់សស្រាំបំផុត" ។

### តើអង្គការគ្រីស្តបរិស័ទដោះស្រាយបញ្ហានេះដោយរបៀបណា?

ដូចគ្នានេះដែរព័ន្ធកិច្ចរបស់ព្រះសហគមន៍កាតូលិក ដែលធ្វើការជាមួយនឹងជនពិការនៅវត្តថាន់ ហើយនិងសាលា *ម៉ារីស ឡារ៉ាឡា* មានអង្គការផ្នែកនិកាយប្រូតេស្តង់មួយចំនួនទៀតដែលធ្វើការជាមួយនឹងជនពិការដែរ ។

ការដែលគួរឲ្យចាប់អារម្មណ៍ណាស់នោះគឺ ការដែលយើងបានឃើញអង្គការមនុស្សធម៌ ដូចជាអង្គការបំរើជនក្រីក្របានលើកបញ្ហាពិការភាពនេះឡើងនៅក្នុងសហគមន៍របស់គេ នៅក្នុងស្រុកមានជ័យ ។

វេជ្ជបណ្ឌិត *ស៊ូ ជែក* រៀបរាប់ពីការងាររបស់អង្គការបំរើជនក្រីក្រថាៈ "យើងខំព្យាយាមប្រមូលកុមារឲ្យចូលរៀនឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ធ្វើការតស៊ូមតិនៅក្នុងសាលារៀននៅតាមមូលដ្ឋានជំនួសឲ្យកុមារទាំងឡាយនោះ ហើយផ្តល់សម្ភារៈសិក្សាដែលចាំបាច់ ដើម្បីជំរុញឲ្យកុមារទាំងនោះចូលសាលារៀនតាមដែលអាចធ្វើបាន ។ ឧទាហរណ៍ យើងសាងសង់កន្លែងសំរាប់កុមារលេង ។ មួយអាទិត្យម្តងយើងមានពេលសំរាប់ឲ្យកុមារលេង ឬព្យាបាលដោយចលនាដល់កុមារ ដែលអ្នកថែទាំកុមាររបស់យើងបង្រៀនលំហាត់ប្រាណដ៏សមរម្យដល់កុមារ ជួយជំរុញលើកទឹកចិត្ត និងផ្តល់នូវដំបូន្មានស្តីពីការថែទាំកូនដល់ឪពុកម្តាយ" ។

អង្គការបំរើជនក្រីក្រមិនផ្តល់ឲ្យឪពុកម្តាយមានការច្រឡំឡើយ ។ "យើងបញ្ជាក់ថា វាគឺជាការប្តូរផ្តាច់របស់អ្នកថែទាំដល់កុមារនោះទៅវិញទេ ដែលថានឹងជួយឲ្យក្មេងនោះមានភាពប្រសើរឡើង មិនមែនជាឯកទេសរបស់យើងទេ ហើយយើងបញ្ជាក់ទៀតថា គឺវាត្រូវស៊ីពេលយូរ មានដំណើរការយឺត ។ ហេតុដូច្នេះហើយ យើងធ្វើនូវអ្វីទាំងអស់ដែលយើងអាចធ្វើបាន ដើម្បីបន្តគាំទ្រគ្រួសារទាំងមូល ដោយបញ្ជាក់ឲ្យគេដឹងច្បាស់ពីដំបូន្មានដែលយើងបានផ្តល់គេ ឧទាហរណ៍ ដូចជារបៀបហាត់ធ្វើចលនានៃសរីរាង្គ ។ ការងាររបស់យើងក៏ផ្តល់ឱកាសដ៏សំខាន់សំរាប់ឲ្យគ្រួសារគេបានជួបជុំគ្នា ។ យើងសម្របសម្រួលក្នុងការតភ្ជាប់រវាងគ្រួសារចាស់ និងគ្រួសារថ្មី ដើម្បីឲ្យគេអាចលើកទឹកចិត្តគ្នាតាមការចំរើនលូតលាស់ដែលអាចកើតឡើងនោះ ។ ការធ្វើបែបនេះមានទម្ងន់ធ្ងន់ និងជះឥទ្ធិពលយ៉ាងខ្លាំងច្រើនជាងនូវអ្វីដែលយើងគ្រាន់តែនិយាយទៅទៀត" ។

គេក៏ត្រូវទទួលរងនូវការមានគំនិតអគតិចំពោះពិការភាពផងដែរ ដែលអ្នកខ្លះត្រូវទទួលរងការមានគំនិតអគតិចំពោះជាតិសាសន៍ផងដែរ ។ "យើងកំពុងសំគាល់ឃើញថា ខ្មែរ ចាម (ខ្មែរអ៊ីស្លាម) និងចំនួនក្មេងនៃជនជាតិវៀតណាមកំពុងកើនឡើង ។ បុគ្គលិកម្នាក់របស់យើងអាចនិយាយភាសាវៀតណាមបានល្អណាស់ ហើយមណ្ឌលសុខភាពរបស់យើងនៅប្រចាំស្រុកនោះ មានគ្រួសារវៀតណាមជាច្រើនដែលសង្គមគេមិនសូវរាប់រក ហេតុដូច្នេះហើយទើបមានការពិបាកក្នុងការទទួលការថែទាំសុខភាពនៅប្រទេសកម្ពុជា"។



រូបទី២ លោក សំអឿន

នាយកសមាគមកម្ពុជាសំរាប់អភិវឌ្ឍកសិករ និងអ្នកក្រីក្រ

មានអង្គការមួយទៀតកំពុងធ្វើការក្នុងវិស័យនេះដែរ គឺសមាគមកម្ពុជាសំរាប់អភិវឌ្ឍកសិករ និងអ្នកក្រីក្រនៅខេត្តកំពត ។ លោក សំអឿន ជានាយករបស់សមាគម(រូបទី២) ខ្លួនឯងផ្ទាល់ជាជនពិការ ហើយដើរតួសំខាន់ ជាគំរូដ៏ប្រពៃ ។ គាត់បានបង្ហាញប្រាប់ថា ដោយសារមានជំនួយមកពីព្រះជាម្ចាស់ និងការប្តេជ្ញាចិត្តផ្ទាល់ខ្លួន បុគ្គលរូបនោះអាចធ្វើការពិសេសទាំងឡាយបាន ។ នៅពេលថ្មីនេះគាត់បានប្រមូលផ្តុំចងក្រងរូបថតរបស់កុមារពិការជាច្រើននៅក្នុងសហគមន៍ (សូមមើលរូបទី៣)



រូបទី ៣ក) កុមារកំពុងលេង



រូបទី ៣ខ) កុមារជួយធ្វើកិច្ចការផ្ទះ

នៅក្នុងការបង្ហាញរូបថតនោះ តាមទស្សនៈរបស់គាត់បញ្ជាក់ប្រាប់ថា បើសិន អំពើអ្វីមួយដែលយើងអាចធ្វើបាន នោះគួរតែប៉ុនប៉ងធ្វើឲ្យបានទៅ ។ កុមារ ចូលសាលារៀន ដាំស្ល លេង ជួយធ្វើការផ្ទះ និងការងារស្រែចំការជាមួយនឹង មិត្តភក្តិរបស់ខ្លួន ។ កម្មវិធីរបស់អង្គការនោះ គឺជួយគាំទ្រដល់គ្រួសារក្រីក្រ តាមរយៈធនាគារគោ ជ្រូក ដែលអាចជួយដល់គ្រួសារទាំងឡាយណា ដែលលំបាកតោកយ៉ាកជាងគេ ដោយព្រោះមានកូនពិការនៅក្នុងបន្ទុក (ឧទាហរណ៍ នៅពេលដែលសមាជិកគ្រួសារនោះមិនអាចធ្វើការបាន ព្រោះ ត្រូវនៅមើលថែកូនពិការ) ។

កុមារទាំងនោះជួនកាលពិការធ្ងន់ធ្ងរ ដែលជាហេតុធ្វើឲ្យគ្រួសារ នោះមិនចង់ទុក ឬមិនអាចថែរក្សាគេបាន ។ ឪពុកម្តាយខ្លះដែលមានកូនពិការ ធ្ងន់ធ្ងរនោះ បែរទៅរកការចង់ធ្វើឃាតកុមារនោះ ។ សូម្បីតែការនេះមិនបាន កើតមានឡើងកាលពីនៅទារកក៏ដោយចុះ តែអាចស្លាប់ដោយសារជម្ងឺកង្វះ ជីវជាតិ គ្រុនចាញ់ ឬជម្ងឺផ្លូវដង្ហើមនៅពេលអាយុមួយខួបដំបូង ។ បើសិនជា កុមារនោះអាចឆ្លងផុតពីការស្លាប់នៅពេលជាទារក កុមារនោះប្រហែលជាអាច រស់នៅមួយរយៈពេល ហើយការនោះតម្រូវឲ្យមានការប្តូរផ្តាច់ក្នុងការថែរក្សា រយៈពេលយូរ ។

ការផ្តល់ការថែទាំជាក្រុមនៅតាមផ្ទះនៅពេលថ្មីៗនេះ ដែលគាំទ្រ ដោយអង្គការ *វ៉ាយវ៉ាម* និង *អ៊ីរ៉ុក ផាក់* ចំពោះកុមារខ្លះដែលមានបញ្ហាពិការធ្ងន់ ធ្ងរ ។ ពួកគេបានចាប់ផ្តើមឡើងក្នុងគោលបំណងបង្កើតស្ថាប័នដ៏ធំមួយសំរាប់ កុមារដែលពិការ ហើយត្រូវគេបោះបង់ចោល ។ ការងារនោះទទួលស្គាល់ពី សមត្ថភាពរបស់កុមារដែលកុមារត្រូវទទួលបាន ដូចជាសិទ្ធិទទួលភាពថ្លៃថ្នូរ សេចក្តីស្រឡាញ់ ការគាំទ្រ និងការថែទាំនៅក្នុងសហគមន៍ ។ ការមានសេចក្តី មេត្តាករុណាដ៏សកម្មចំពោះកុមារពិការនោះ ហាក់បីដូចកើតចេញមកពីចរិក លក្ខណៈរបស់គ្រីស្តបរិស័ទជាចម្បង ។ រីឯជំនឿគ្រីស្តបរិស័ទមិនមែនគ្រាន់

តែជាជំនឿតែមួយគត់ ដែលត្រូវមានសេចក្តីមេត្តាករុណានោះទេ មានអង្គការមួយចំនួនទៀតដែលបានធ្វើការជាមួយកុមារពិការផុសចេញពីជំនឿផ្សេងនោះគឺមានតិចតួចណាស់ ។

## តើអ្វីទៅជាភាពពិការ និងអ្វីទៅជាភាពចុះខ្សោយ?

អង្គការ *ធាហ្វាន់* ជឿជាក់ថា យើងគួរផ្តោតចិត្តទុកដាក់លើអ្វីដែលកុមារអាចធ្វើបានជាជាងលើអ្វីដែលគេមិនអាចធ្វើបាន ។ អង្គការសុខភាពពិភពលោកមានចែងច្បាប់ជាពិសេសសំរាប់បែងចែកឲ្យដាច់ពីភាពទន់ខ្សោយ និងភាពពិការ (មើលនៅរូបភាពទី៨) ដែលជួយបំរើឲ្យគោលគំនិតនៃការអសមត្ថភាព ។ ការនេះជួយឲ្យជៀសចេញពីគំរូផ្នែកសុខាភិបាលដ៏តឹងតែងដែលមានបំណងចង់បង្ហាញពីមូលហេតុទាំងឡាយ និងផលប៉ះពាល់ពីភាពពិការនេះតាមមធ្យោបាយមួយ ដែលបង្ហាញពីចំណុចវិជ្ជមានឲ្យបានប្រសើរឡើងថែមទៀត ។ ពាក្យថា អសមត្ថភាព និងពិការ គឺគេបានយកគំនិតវិជ្ជមាននៃសកម្មភាព និងការចូលរួមមកដាក់ជំនួសវិញ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងត្រូវចងចាំថា "ពាក្យសំដីអាចកែស្ថានការណ៍នយោបាយបាន និងមានការផ្សព្វផ្សាប់បានល្អណាស់ ប៉ុន្តែមនុស្សដែលពិការភាគច្រើន គឺនៅឯកោត្រមង់ត្រមោចតែឯង គ្មានទិសដៅក្នុងជីវិត គ្មានមនុស្សរាប់រក និងជាទូទៅគេបានកាត់ចេញពីសង្គមតែម្តង"[៦] ការគ្រាន់តែប្រើពាក្យសំដីនោះមិនគ្រប់គ្រាន់ទេ ទាល់តែអាកប្បកិរិយាដ៏ស្មោះសរដូចជាព្រះគ្រីស្ទក្នុងឋានៈជាអ្នកបំរើនោះទេវិញទេដែលប្រសើរ ។

---

[៦] Nigel Poulton of World Corncer, personal communication.

| ពាក្យ | និយមន័យ |
|---|---|
| ភាពទន់ខ្សោយ | ការបាត់បង់ ឬការមានភាពមិនធម្មតាចំពោះអវៈយវៈណាមួយ (គឺមានន័យថា រចនាសម្ព័ន្ធនៃរាងកាយ) ឬក៏មុខណាមួយរបស់រាងកាយ(ដូចជាផ្នែកមុខងារផ្លូវចិត្ត) ។ ផ្នែកនេះគឺគិតរួមទាំងមុខងាររបស់ខួរក្បាល ។ |
| សកម្មភាព | មនុស្សម្នាក់អាចធ្វើសកម្មភាពងាយៗបាន (ដូចជាការចាប់កាន់ កំរើកជើង សំឡឹងមើល) រហូតជំនាញពិបាកៗ និងអាកប្បកិរិយាពិបាកៗជាច្រើន (ដូចជាការនឹកចងចាំពីព្រឹត្តិការណ៍កាលពីអតីតកាល ឬការល្បងផ្នែកចំណេះដឹង) ។ |
| សកម្មភាពដែលមានដែនកំណត់ (មានភាពពិការពីមុន) | ពិបាកក្នុងការសម្តែងអ្វីមួយ ក្នុងការសម្រេចឲ្យបានអ្វីមួយ ឬការបំពេញបានកិរិតរបស់មនុស្សនេះ ដោយសារតែមានការឈឺចាប់ មានភាពមិនប្រក្រតី ធ្វើការនោះយឺតពេក លឿនពេក ឬមិនត្រូវចំពេល មិនត្រូវចំកន្លែង ។ |
| ការចូលរួម | ការចូលរួមមានគ្រប់ផ្នែកទាំងអស់នៃទិដ្ឋភាពរបស់-ជីវិតរស់នៅរបស់មនុស្សរួមទាំងការពាក់ព័ន្ធ ការប្រព្រឹត្តិ ទំនៀមទំលាប់ ឬការធ្វើអ្វីមួយដែលមានលក្ខណៈរួមជាសង្គម ។ |
| ការចូលរួមដែលមានដែនកំណត់ | ភាពមិនអំណោយផលរបស់មនុស្សម្នាក់ ដែលភាពទន់ខ្សោយនោះមានការកើតឡើង ឬក៏កាន់តែយ៉ាប់យ៉ឺនខ្លាំងឡើងថែមទៀត ដោយសារតែស្ថានការណ៍នៅជុំវិញ និងកត្តាខ្លះៗនៃបុគ្គលនោះផ្ទាល់តែម្តង ។ |

Source: WHO ICIDH - 2 (1997)

*រូបទី ៤: WHO International Classification of Impairments and Handicaps.*

គំរូផ្អែកវេជ្ជសាស្ត្រស្តីពីភាពពិការនោះ គឺផ្សាភ្ជាប់គ្នាបានល្អណាស់ ដោយមានវេជ្ជបណ្ឌិតជាច្រើនសំឡឹងឃើញភាពទន់ខ្សោយនោះថា "ជាការលូតលាស់មិនធម្មតា" ដែលត្រូវការ "ការកែតម្រូវ" "ការព្យាបាល" ឬ "ការជំនះលើការទាំងនោះឲ្យបាន" ។ ការនេះគឺផ្អែកទៅលើគំនិតដែលថា រូបកាយរបស់មនុស្សអាចកែកុនបាន តែបរិយាកាសសង្គមរស់នៅមិនអាចកែកុនបានឡើយ ។ ភាពពិការដែលមើលតាមគំរូរបស់សង្គមរស់នៅនោះ គឺកើតឡើងដោយគ្រូពេទ្យនៅតាមសហគមន៍ដែលបានសង្កត់ធ្ងន់ថា ភាពពិការឬការអសមត្ថភាពនេះ គឺមានទំនាក់ទំនងទៅនឹងបុគ្គលនោះផ្ទាល់ និងបរិយាកាសរស់នៅរបស់គេ ហើយបានសង្កត់ធ្ងន់ទៀតថា សង្គមមានតួនាទីសំខាន់ក្នុងការធ្វើឲ្យមនុស្សម្នាក់នោះក្លាយជាមនុស្សពិការរហូតនោះ[២] ។

## តើព្រះគម្ពីរចែងយ៉ាងម៉េចអំពីភាពពិការនេះ?

*ប៉ុន្តែអស់ទាំងអវយវៈក្នុងរូបកាយដែលមើលទៅដូចជាខ្សោយជាងគេនោះ មានប្រយោជន៍ជាជាងវិញ ហើយអវយវៈណាក្នុងរូបកាយ ដែលយើងស្មានថាមិនគួររាប់អានប៉ុន្មាន នោះយើងរាប់អានលើសទៅទៀត... អ្នករាល់គ្នាជារូបកាយនៃព្រះគ្រីស្ទ ហើយជាអវយវៈរបស់រូបកាយរៀងខ្លួន* [៣] ។

កុមារម្នាក់ៗព្រះជាម្ចាស់បង្កើតមកមានលក្ខណៈពិសេសជារូបឆ្លុះរបស់ព្រះអង្គ ហើយមានតម្លៃជាទីបំផុត[៤] ។ បើសិនភាពចំរើនវ័យធំឡើងត្រូវកំណត់ឲ្យឃើញច្បាស់ថាជា "ការសម្រេចតាមខ្នាតយ៉ាងពេញលេញរបស់ព្រះគ្រីស្ទនោះ"[៥] ដែលព្រះអង្គដ៏ជាព្រះមកគង់នៅក្នុងរូបកាយរបស់

[២] Hartley, Sally, and Sheilah Wirz, 1993.

[៣] *១កូរិន. ១២:២២-២៣,២៧*

[៤] *លោកុ. ១:២៦*

[៥] *អេភេសូរ ៤:១៣*

មនុស្ស"[៦] អ៊ីចឹងកុមារទាំងអស់ក៏ត្រូវមានដែនកំណត់សំរាប់ការលូតលាស់ដែរមុននឹងឈោងទៅដល់វ័យមួយដែលគេត្រូវសម្រេចឲ្យបាននោះ ។ គ្រីស្តបរិស័ទត្រូវជឿចំពោះការនេះថាជាការពិត មិនថាឡើយកុមារនោះមានបញ្ហាក្នុងការចំរើនលូតលាស់ផ្នែករូបកាយ ឬផ្នែកសតិបញ្ញានោះទេ ។ តាមពិតទៅគ្មាននរណាម្នាក់មានលក្ខណៈគ្រប់ពេញលេញ ឬមានការចំរើនលូតលាស់ល្អឥតខ្ចោះនោះទេមុនពេលដែលយើងឡើងទៅស្ថានសួគ៌ ។ សូម្បីតែព្រះយេស៊ូក៏ត្រូវរស់នៅក្នុងសណ្ឋានជាមនុស្សដែលមានដែនកំណត់ដែរ ។ លោកវេជ្ជបណ្ឌិត *ភីធើ សែបួថាំ* ដែលធ្លាប់ធ្វើការជាមួយអង្គការបំរើជនក្រីក្រនៅក្នុងប្រទេសកម្ពុជាបាននិយាយថា "កុមារដែលមានភាពមិនប្រក្រតី ឬគ្មានអវយវៈណាមួយនោះ ត្រូវការការលើកទឹកចិត្តដើម្បីឲ្យគេអាចឈោងចាប់ដល់កិរិតជាសក្តានុពលមួយដែលព្រះប្រទានឲ្យដល់គេនោះ" ។

ទោះបីជាយ៉ាងណាក៏ដោយ "គំនិតស្តីអំពីភាពគ្រប់លក្ខណៈ គឺជាផ្នែកមួយសំខាន់ចំពោះការទទួលស្គាល់ និងការយល់ថា មានភាពមិនប្រក្រតីនោះចាត់ទុកថាជាផ្នែកមួយតូចក្នុងនិស្ស័យលក្ខណៈរបស់បុគ្គលរូបនោះទៅវិញទេ" ។ ហេតុដូច្នេះហើយបានជា បណ្ឌិត *ណាន់ស៊ីឡេន* ដែលខ្លួនគាត់ផ្ទាល់ជាអ្នកពិការនិយាយថា កុមារដែលមានភាពពិការ គឺមាន "ភាពពេញលេញជាមនុស្ស" តាមលក្ខណៈរបស់គេទៅហើយ គឺគ្រាន់តែមានការជិតដាមជាប់នូវផ្នត់គំនិតថាខ្លួនឯងមិនជាបើប៉ុណ្ណោះ ។ "ការនេះក៏ធ្វើឲ្យផ្នត់គំនិតដែលថារាងកាយពិការនោះ មានន័យថាមិនមែនពិការទាំងអស់នោះទេ បានសេចក្តីថាគេមានគំនិត សមត្ថភាពក្នុងការរួមភេទ មានសេចក្តីត្រូវការ និងមានបំណងប្រាថ្នាដូចជាអ្នកដែលមិនពិការនោះដែរ"[៧]។

---

[៦] *កូឡុស ២:៩*

[៧] *ណាន់ ស៊ី ឡេន ទៅផ្នែកប្រាស្រ័យទាក់ទងបុគ្គលិក*

តែផ្ទុយទៅវិញ នៅក្នុងប្រទេសកម្ពុជា កុមារដែលមានភាពពិការនោះ តែងតែគេមើលមកហាក់ដូចជារស់នៅដើម្បីបង្ហិនធនធាន ។ ហេតុដូច្នេះហើយបានជាសហគមន៍ដូចជាមិនសូវរាប់រកគេ ភាគច្រើនផ្នែករដ្ឋាភិបាល និងមន្ទីរសុខាភិបាល ហើយសូម្បីតែគ្រួសាររបស់គេផ្ទាល់នោះក៏មិនសូវរាប់រកដល់គេប៉ុន្មានដែរ ។

យើងទាំងអស់គេត្រូវតែពិសោធនូវសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ។ តែគួរឲ្យសោកស្តាយណាស់ដែលកុមារពិការទាំងឡាយបែរជាទទួលនូវការមិនអើពើ និងមិនទទួលបាននូវភាពកក់ក្តៅនៃក្តីស្រឡាញ់តាំងពីនៅតូចមកម្ល៉េះ ។ ដូច្នេះក្រុមជំនុំត្រូវតែឆ្លើយតប ត្រូវតែផ្តល់ជំរើសដ៏ល្អមួយ និងផ្តល់បរិយាកាសដែលប្រកបដោយសេចក្តីស្រឡាញ់ ។ ប្រាកដជាមានការឈឺចាប់មែនហើយចំពោះការដែលមាន "លក្ខណៈខុសពីគេឯងនោះ" ប៉ុន្តែនៅក្នុងអាណាចក្ររបស់ព្រះមានលក្ខណៈផ្ទុយពីនោះ "ដើម្បីនឹងធ្វើឲ្យអ្នកប្រាជ្ញមានសេចក្តីខ្មាសវិញ ទ្រង់បានរើសពួកកំសោយនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឲ្យពួកខ្លាំងពូកែមានសេចក្តីខ្មាស"[៨] ។

តួអង្គសំខាន់ខ្លះដូចជាលោកម៉ូសេ[៩] និង លោកប៉ូល[១០] មានភាពទន់ខ្សោយ ។ លោក *ម៉េល ហាន* មកពី "សកម្មភាពក្រុមជំនុំចំពោះភាពពិការ" បានបង្ហាញការណែនាំឲ្យយោបល់ថា "មិនអាចករណីបែបនេះកើតឡើងឡើយ បើព្រះជាម្ចាស់មិនឲ្យមានអ្នកទន់ខ្សោយនៅជុំវិញយើងទេនោះ" ។ ទាំងលោកម៉ូសេ និងលោកប៉ូល ព្រះជាម្ចាស់បានជ្រើសរើសជាពិសេសសំរាប់ការងារផ្សាយព្រះរាជសាររបស់ព្រះអង្គ តែទោះជាយ៉ាងណាក៏ដោយព្រះជាម្ចាស់បង្ហាញឲ្យដឹងពីលោកម៉ូសេដែលទាក់ទងពីសំដីដំឡាន់របស់គាត់

---

[៨] *១កូរិន. ១:២៥-៣១*

[៩] *និក្ខមនំ ៤:១០-១១*

[១០] Faith Bowers, 1996.

"អញបង្កើតឯងមកដូច្នេះឯង" ។ សេចក្តីបង្រៀនរបស់លោកប៉ូលដែលប្រៀបធៀបពីរូបកាយនៅក្នុងបទគម្ពីរ១កូរិនថូស ១២ បានបង្ហាញឲ្យឃើញថាព្រះជាម្ចាស់បង្កើតមនុស្សទាំងអស់(រួមទាំងកុមារដែលមានការលូតលាស់មិនប្រក្រតីផង) មកដើម្បីបង្ហាញពីការពឹងពាក់អាស្រ័យគ្នាទៅវិញទៅមករបស់មនុស្ស (ជាជាងពឹងលើខ្លួនឯង ឬក៏គ្រាន់តែសន្មត់លើភាពជាម្ចាស់លើខ្លួនឯង) ។

ភាពពិការមិនមែនដោយសារតែអំពើបាប ឬមកពីកុមារ ឬឪពុកម្តាយរបស់ក្មេងនោះខ្វះជំនឿនោះទេ ។ ប្រហែលអាចជាការបើកសម្តែងយ៉ាងអស្ចារ្យពីព្រះជាម្ចាស់ចំពោះកុមារដែលមានភាពមិនប្រក្រតីនោះ ដើម្បីឲ្យដឹងថាព្រះជាម្ចាស់ស្រឡាញ់ដល់គេដោយឥតលក្ខខ័ណ្ឌ ព្រមទាំងឲ្យគេដឹងទៀតថា គេអាចចូលទៅរកព្រះអង្គដោយសេចក្តីអធិស្ឋាន និងថ្វាយបង្គំព្រះអង្គដូចជាមនុស្សដទៃទៀតដែរ ។ ព្រះអម្ចាស់មានព្រះបន្ទូលថា៖ "អញបានហៅចំឈ្មោះឯង ឯងជារបស់ផងអញ" (អេសាយ ៤៣:១) ។[១១]

ព្រះយេស៊ូផ្ទាល់បានសម្រេចព្រះហឫទ័យបន្សល់ទុកស្លាកស្នាមនៃការជាប់ឆ្កាងបន្ទាប់ពីព្រះអង្គរស់ពីសុគតឡើងវិញ នៅក្នុងឋានៈដែលព្រះអង្គជាព្រះដែលមានរូបកាយល្អឥតខ្ចោះនោះ ព្រះអង្គមិនគួរទុកស្លាកស្នាមលើអង្គទ្រង់ឡើយ។ តែផ្ទុយទៅវិញព្រះយេស៊ូត្រាស់ហៅពួកសិស្សរបស់ព្រះអង្គឲ្យមកស្ទាបស្នាមរបួសដែលនៅជិតដាមលើអង្គទ្រង់ទៅវិញ ។ ការធ្វើបែបនោះ គឺព្រះអង្គកំពុង"ជំរុញលើកទឹកចិត្តដល់ពួកអ្នកដែលគ្មានភាពពិការឲ្យឈប់រើសអើងដល់ពួកអ្នកដែលមានភាពពិការនោះ"[១២] ។ "យើងទាំងអស់គ្នាបានជាដោយស្នាមរបួសនៅលើរូបអង្គទ្រង់" ។[១៣]

---

[១១] Faith Bowers, 1996.

[១២] Taylor & McCloughry, 1998.

[១៣] *អេសាយ ៥៣:៥*

ក្រុមជំនុំសម័យគម្ពីរសញ្ញាថ្មីបន្តនូវការជំរុញលើកទឹកចិត្តឲ្យចូលទៅជិតពួកអ្នកដែលតាមធម្មតាគេមិនចូលចិត្តនឹងពួកនោះ ហើយថែមទាំងជំរុញលើកទឹកចិត្តឲ្យស្រឡាញ់ពួកគេដោយឥតលក្ខខ័ណ្ឌទៀតផង ។ រឿងសាសន៍សាម៉ារីដ៏សប្បុរស នោះគឺជាគំរូមួយដ៏ល្អសំរាប់យើង ។ *ជីន វ៉ែនីយេ៉* (Jean Vannier) បានស្ថាបនាសហគមន៍មួយឈ្មោះថា *ឡាកឆ៍* (L' Arche) ដែលមានទាំងមនុស្សពិការ និងមនុស្សមិនពិការរស់នៅជាមួយគ្នាក្នុងសហគមន៍ ។ *វ៉ែនីយេ៉* បានសង្កេតឃើញថា "ការស្រឡាញ់អ្នកណាម្នាក់មិនមែនត្រូវធ្វើអ្វីសម្រាប់គេនោះទេឡើយ ប៉ុន្តែត្រូវឲ្យគេដឹងថាគេមានតម្លៃទៅវិញទេ ទើបបញ្ជាក់ថាយើងស្រឡាញ់គេ" ។ គឺជាការសំខាន់ណាស់ដែលកុមារមានភាពពិការមិនត្រូវបានគេមើលឃើញថា គេកើតឡើងមកនេះគ្រាន់តែធ្វើឲ្យអ្នកដទៃមានឱកាសបំរើព្រះឲ្យបានកាន់តែប្រសើរឡើងនោះប៉ុណ្ណោះទេ ។ ការយល់បែបនេះអាចបញ្ជាក់ឲ្យឃើញថា អ្នកបំរើនោះហាក់ដូចជាមានតម្លៃសំខាន់ជាងអ្នកដែលទទួលនូវការបំរើពីគេទៅវិញ ។

### តើអ្វីទៅជាគោលនយោបាយដ៏ប្រសើរបំផុត ដើម្បីជួយដល់កុមារដែលមានភាពពិការ?

ប្រវត្តិសាស្ត្របានបង្ហាញឲ្យដឹងថា កុមារដែលមានភាពពិការ ជាពិសេសចំពោះអ្នកដែលមានបញ្ហាផ្នែក "សតិបញ្ញាល្ងូតល្ងង់មិនធម្មតា" ត្រូវបានគេយកទៅរក្សាទុកនៅក្នុងជំរំដ៏ធំមួយកន្លែង ។ ឧទាហរណ៍ នៅទីក្រុង *ឡុនដុន* មានមន្ទីរពេទ្យសំរាប់ថែរក្សាមនុស្សមានបញ្ហាផ្នែកសតិបញ្ញាអន់ថយជាច្រើនកន្លែងនៅពទ្ធជុំវិញ ។ ជំរើសដ៏ល្អដែលកុមារអាចទទួលបាននោះគឺគេដាក់កុមារទាំងនោះនៅក្នុងស្ថាប័នពិសេសមួយ ដូចជាសាលារៀនសំរាប់កុមារពិការភ្នែក ។ គំនិតយោបល់ទាំងនេះត្រូវគេចម្លងតគ្នាមកដល់ប្រទេសដែលកំពុងអភិវឌ្ឍ ហេតុដូច្នេះបានជាមកទល់ពេលនេះរដ្ឋាភិបាល និងអង្គការ

គ្រីស្តបរិស័ទនានាមើលឃើញថាស្ថាប័នទាំងនេះជាមធ្យោបាយសំរាប់ដោះស្រាយជាមួយ "បញ្ហា" នៃការមានភាពពិការនេះ ។

តែទោះជាយ៉ាងណាក៏ដោយ រឿងរ៉ាវទាំងឡាយនោះចាប់ផ្តើមផ្លាស់ប្តូរបន្តិចម្តងៗ ។ ការស្រាវជ្រាវរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិបង្ហាញឲ្យឃើញថា[១៨] សេវាកម្មដែលគេបញ្ជូនឲ្យទៅជួយដល់មនុស្សដែលមានភាពពិការនៅក្នុងបណ្តាប្រទេសដែលមិនទាន់មានការអភិវឌ្ឍន៍នៅឡើយ នោះនឹងអាចទទួលនូវអត្ថប្រយោជន៍ពីការរួមបញ្ចូលគោលការណ៍ដូចខាងក្រោមនេះ ៖

១. ធ្វើឲ្យគ្រួសារ និងសហគមន៍ចូលរួមគាំទ្រជាមួយគ្នា ។
២. ផ្តល់កម្លាំងចិត្តដល់អ្នកដែលមានភាវពិការ ឲ្យគេយល់ពីតម្លៃរបស់ខ្លួនគេផ្ទាល់ ។
៣. ផ្លាស់ប្តូរឥរិយាបថរបស់មនុស្សដែលធ្លាប់មានចំពោះអ្នកដែលមានភាពពិការ ។

គោលការណ៍ទាំងនេះជាកញ្ចក់ឆ្លុះបញ្ចាំងពីគោលការណ៍គាំទ្ររបស់គ្រួសារនៅក្នុងព្រះគម្ពីរដែលជួយគាំទ្រ និងលើកទឹកចិត្តដល់អ្នកដែលងាយទទួលនូវការរងគ្រោះ និងផ្តល់ការស្នាក់អាស្រ័យនៅដោយឥតមានការប្រកាន់ពណ៌សម្បុរនោះឡើយចំពោះអ្នកដែលមិនមែនដូចជារូបយើងនោះ ។

ការនេះគេសង្ឃឹមថា មានការស្តាបនាសហគមន៍បានយ៉ាងល្អនឹងជួយផ្តល់សមត្ថភាពគ្រួសារជាច្រើន ដើម្បីថែរក្សាកូនដែលមានភាពពិការឲ្យរស់នៅជាមួយពួកគេផ្ទាល់ដោយធ្វើការរួមគ្នាជាសហគមន៍ ក្នុងការគាំទ្រគ្រប់មធ្យោបាយដើម្បីធ្វើការជាមួយកុមារដែលមានបញ្ហាបែបនោះ ។ ដោយធ្វើការងារបែបនោះ ពួកគេអាចមានបទពិសោធន៍ពីការទទួលផលប្រយោជន៍ និងក្តីអំណរ ព្រមទាំងទុក្ខលំបាក និងសេចក្តីបារម្ភជាមួយគ្នាផងចំពោះការបីបាច់

[១៨] Helander, 1993.

ថែទាំកូនដែលមានភាពពិការ ។ មិនថាឡើយកុមារនោះអាចស្នាក់នៅឯផ្ទះ ឬមិនអាចនោះទេ គឺវាអាស្រ័យលើស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់គេ សេវាថែទាំនៅក្នុងសហគមន៍ដែលមនុស្សទាំងនោះគេបានដឹង ហើយជួនកាលវាអាស្រ័យលើអ្វីដែលវេជ្ជបណ្ឌិត ឬឆ្មបបានប្រាប់ដល់គ្រួសារនោះនៅពេលដែលទារកនោះកើតមក ។

ប្រហែលជាវាអាចអាស្រ័យលើទំហំនៃភាពទន់ខ្សោយរបស់គេ និងអាស្រ័យលើការទទួលខុសត្រូវថែទាំពីសំណាក់ បង ជីដូនជីតា ឬមនុស្សពេញវ័យដទៃទៀតនៅក្នុងគ្រួសារនោះទៅវិញទេ ។ អ្នកដែលទទួលនូវការថែទាំជាសំខាន់នោះ គឺសាច់ញាតិជិតៗរបស់កុមារនោះ ។ សមត្ថភាពនៃការងារថែទាំដល់កុមារពិការនោះ គឺវាអាស្រ័យលើការងាររបស់គ្រួសារនោះ ដូចជាការងារផ្ទះ សេចក្តីត្រូវការផ្នែកការរៀនសូត្រជាដើម ។ ពួកគេប្រហែលជាត្រូវការការគាំទ្រពីសហគមន៍ និង កន្លែងដែលមានក្រុមជំនុំគ្រីស្ទបរិស័ទនៅក្នុងសហគមន៍របស់គេនោះ ។

មធ្យោបាយដទៃទៀតចំពោះបញ្ហានេះ អាចធ្វើទៅបានតាមរយៈការតស៊ូមតិដែលទាក់ទងទៅនឹងឥរិយាបថរបស់សាធារណៈជន ការថែទាំសុខភាព ការអប់រំ និងសេវាសង្គម/ក្រុមអ្នកដែលមានវិជ្ជាជីវៈដោយស្មគ្រ័ចិត្តដែលតាមពិតទៅឪពុកម្តាយត្រូវតែទទួលនូវការយល់ដឹងយ៉ាងច្បាស់ពីរឿងនេះ គឺត្រូវមើលឲ្យឃើញពីសមត្ថភាពរបស់កូននោះវិញ ជាជាងមើលឃើញតែភាពពិការរបស់គេ ។ ទោះបីជាយ៉ាងណាក៏ដោយ តាមធម្មតាឥរិយាបថទាំងឡាយនោះ ត្រូវតែចាប់ផ្តើមឡើងចេញពីយើងផ្ទាល់រួមជាមួយនឹងក្រុមជំនុំផង ។ តើយើងស្វាគមន៍ជនពិការឲ្យចូលរួមជាមួយយើងនៅក្នុងក្រុមជំនុំយ៉ាងកក់ក្តៅ ឬយើងមិនអើពើដាក់គេ និងប្រព្រឹត្តមិនសមរម្យតាមទម្លាប់ដែលយើងធ្លាប់ធ្វើពីមុនមកនោះ ឬយ៉ាងណា? យើងត្រូវតែទូលសូមឲ្យព្រះយេស៊ូជួយដោះឲ្យរួចនូវសេចក្តីភ័យខ្លាច និងការរើសអើងទាំងឡាយដែលយើងមាន ។

## References

Bowers, Faith. *Treat with Special Honour: People with Learning Difficulties in the Life of the Church.* Oxfordshire: Baptist House, 1996.

Hartley, Sally, and Sheilah Wirz. "Investing Models of Service Delivery for People with Communication Disorders in Anglophone Africa," *Work in Progress*, vol. 3. NHCSS. University of London, 1993.

Helander, E. *Prejudice and Dignity: an Introduction to Community Based Rehabilitation.* New York: UNDP, 1993.

Horne, Mel. "Did God Create Impairment? A Bible Study." *All People: the Magazine of Church Action on Disability* (1998).

Sidebotham, P. *Child Development and Disability.* Unpublished, 1998.

Taylor, M., and McLoughry. "A Disabled God." *Third Way* (October 1998).

Through the Roof "Roofbreaker Guides." *Guidelines for Involving Children with Disabilities into Church Life.* UK: Through the Roof Ministries, 1999.

Wirz, Shelagh, and Winyard. *Hearing and Communication Disorders.* London: Macmillan, 1993.

Young, F. *Encounter with Mystery: Reflections on L'Arche and Living with Disability.* Darton, Longman & Todd, 1997.

*A group of essays by theologians after visiting the L'Arche communities.*

## Key Resources

Coleridge, Peter. *Disability, Liberation and Development.* Oxford: Oxfam Publications, 1993.

Eiesland, Nancy L. *The Disabled God: Towards a Libertory Theology of Disability.* Nashville: Abingdon, 1994.

*Looks at Jesus being "disabled" on the cross, and then at the meeting with the disciples after the resurrection.*

Ingstad, B. and Whyte, SR, ed. *Disability and Culture.* Berkeley: University of California Press, 1995.

Potter D. *Am I Beautiful . . . or What?* Oxford: Scripture Union, 1998.
*Information about learning disability, training material for individual or group use, essential guidance on running meetings for people with learning difficulties, a course of teaching materials for such meetings.*

Ransom, Judy Griffith. *The Courage to Care: Seven Families Touched by Disability and Congregational Caring.* Nashville: Upper Room Books, 1994.
*Chronicles the stories of people whose lives were dramatically changed by the caring of congregations, friends, and family. Important book for churches wanting to understand why and how caring is part of what it means to be a community and to offer hospitality.*

Webb-Mitchell, Brett. *God Plays Piano Too: The Spiritual Lives of Disabled Children.* N.p.: Crossroads, 1993.
*The stories of children with disabilities who had wonderful, but often hidden, gifts. Webb-Mitchell shows the church how to welcome and receive the gifts and "reveals the hidden wholeness that lies beneath the broken surface of all our lives."*

Webb-Mitchell, Brett. *Unexpected Guests at God's Banquet: Welcoming People with Disabilities into the Church.* N.p.: Crossroads, 1994.
*This is concerned with learning how to welcome people with disabilities and why doing so is essential for the church. "For it is only when we learn how to be with those who are different from us, and learn how to accept the love of God that we all need, that we will be able to sustain a community that is capable of worshipping God."*

Werner, David. *Disabled Village Children: A Guide for Community Health Workers, Rehabilitation Workers and Families.* Palo Alto, California: Hesperian Foundation, 1994.

____________. *Nothing about Us Without Us.* Palo Alto, California: Hesperian Foundation, 1998.
*Explores innovative aids that can be made at low cost. It also considers how people with disabilities and those without them can learn together.*

## Christian Resource Organizations

Church Action on Disability (CHAD), 50 Scrutton Street, London EC2A 4PH, UK. Tel: 44 171 452 2085; Fax: +44 171 452 2001; email: mlpcfm@aol.com
*Education and awareness raising of disability in churches. Produce access audit, resource pack, study pack and youth pack. Quarterly magazine* All people.

Deaf Christian Network, P.O. Box 212, Doncaster, South Yorkshire, DN2 5XA, UK Tel: +44 1302 369684 (Voice/Minicom); Fax: +44 1302 739660
*Resources for those working with profoundly deaf people.*

Disability Awareness and A Healing Ministry (The Rev. Dr. Nancy Lane). P. O. Box 274, Lansing, NY 14882-0274, USA. Tel: 607-533-4083 Email: nlane1@twcny.rr.com
*Resources for those working with women who have been abused or sexually exploited, including women with disabilities.*

Evangelical Alliance Disability Forum, 186 Kennington Park Road, London SE11 4BT, UK Tel: +44 171 207 2100; Fax: +44 171 207 2150
*Umbrella organization for Christian disability organizations.*

SPRED, Special Religious Education Department (Roman Catholic Church), c/o Brothers of Charity Services, Lissieux Hall, Whittle-le-Woods, Chorley, Lancashire PR6 7DX, UK. Tel: 44 1257 266 311
*Looks at spiritual needs of people with learning difficulties and provides suitable study and worship material.*

Through the Roof, P.O. Box 178, Cobham, Surrey, KT11 1YN Tel/Fax: +44 1932 866333; email: info@throughtheroof.org website: www.jafministries.com/throughtheroof
*The disability outreach of Joni Erickson Tada. Produces a series of one-page "Roofbreaker Guides" about including people with different types of disabilities in the church.*

Torch Trust for the Blind, Torch House, Hallaton, Market Harborough, Leicestershire, LE16 8UJ, UK. Tel: +44 1858 555301; Fax: +44 1858 555371
*Christian resources for blind and visually impaired people.*